**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ...៥៧...សសរ**

# សេចក្ដីសម្រេច
# ស្ដីពី
# ការបង្កើតគណៈកម្មាធិការអាហារូបករណ៍សិស្ស-និស្សិតក្រីក្រ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែ តាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បា ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកា ឱ្យប្រើច្បាប់ ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២១អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការបង្កើតខុទ្ទកាល័ សម្ដេចនាយករដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់

## ស ម្រេ ច

**ប្រការ ១** : ត្រូវបានបង្កើតគណៈកម្មាធិការអាហារូបករណ៍សិស្ស-និស្សិតក្រីក្រ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែ** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**លោកជំទាវ** ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-លោក | **ហ៊ុន ម៉ាណែត** | ប្រធាន |
| ២-លោក | **សុខ ពុទ្ធិវុធ** | អនុប្រធានទី១ |
| ៣-ឯកឧត្ដម | **ស៊ាន ប៊ូរ៉ាត** | អនុប្រធានអចិន្ត្រៃយ៍ |
| ៤-លោក | **ជា ពិសី** | សមាជិក |
| ៥-លោក | **ជួន ជីវិន** | សមាជិក |
| ៦-លោកស្រី | **មាស វិចិត្រា** | សមាជិក |

www.pheakdeylaw.com

ប្រការ ២ : គណៈកម្មាធិការអាហារូបករណ៍សិស្ស-និស្សិតក្រីក្រ មានភារកិច្ចដូចតទៅ :

-អំពាវនាវគ្រឹះស្ថានឧត្តមសិក្សានានា នៅក្នុងប្រទេស និងក្រៅប្រទេស ដើម្បីរកអាហារូបករណ៍

-គ្រប់គ្រង និងបែងចែកដល់សិស្ស-និស្សិតក្រីក្រ នូវអាហារូបករណ៍ ដែលគ្រឹះស្ថានឧត្តមសិក្សានានា ផ្តល់ជូន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**លោកជំទាវ**

-ធ្វើការពិនិត្យបណ្តាសិស្ស-និស្សិតអាហារូបករណ៍ដែលគណៈកម្មាធិការបានផ្តល់ជូន

-ធ្វើរបាយការណ៍ជូន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ប្រការ ៣ : នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសាមីជន ដូចមានរាយនាមក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន